អង្គការសហប្រជាជាតិ A/HRC/23/43

**មហាសន្និបាត**

ការចែកចាយៈ ទូទៅ
ថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៣
ច្បាប់ដើម៖ ភាសាអង់គ្លេស

គណៈកម្មាធិការសិទ្ធិមនុស្ស
**សម័យប្រជុំលើកទី ២៣**
ចំណុចរបៀបវារៈទី ៣
**ការលើកកំពស់ និងការពារសិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រួមទាំងសិទ្ធិទទួលបានការអភិវឌ្ឍ**

# របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពរបស់តុលាការ និងមេធាវី

ដោយលោកស្រី Gabriela Knaul

*សេចក្តីសង្ខេប*

ក្នុងរបាយការណ៍នេះ អ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពរបស់តុលាការនិងមេធាវី ពិនិត្យមើលភាពពាក់ព័ន្ធ និងវិភាគពីលទ្ធភាពក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់បុគ្គលដែលបានចូលមកក្នុងទំនាក់ទំនងផ្នែកច្បាប់តែគ្មានលទ្ធភាពផ្គត់ផ្គង់ការចំណាយនៃការផ្តល់ដំបូន្មានផ្នែកច្បាប់ ការប្រឹក្សា និងតំណាងផ្នែកច្បាប់។ គោលបំនងចម្បងនៃរបាយការណ៍នេះ គឺដើម្បីជំរុញឲ្យរដ្ឋអភិវឌ្ឍ និងអនុវត្តគម្រោងជំនួយផ្នែកច្បាប់ឲ្យមានប្រសិទ្ធិភាព និងមាននិរន្តភាព ដើម្បីអនុញ្ញាតឱ្យបុគ្គលគ្រប់រូបអនុវត្ត និងទទួលបានសិទ្ធិមួយចំនួន រួមទាំងសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិទទួលបានសំណងដោយប្រសិទ្ធិភាព។ អ្នករាយការណ៍ពិសេសពិចារណាឃើញថា ជំនួយផ្នែកច្បាប់គួរត្រូវបានធានាទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ និងករណីដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ និងគួរត្រូវបានបញ្ចូលក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការឬក្រៅប្រព័ន្ធតុលាការ ដែលជាលទ្ធផលរួមចំណែកលុបបំបាត់ឧបសគ្គដែលរារាំងដល់ការទទួលបានយុត្តិធម៌តាមរយៈការផ្តល់ជំនួយដល់មនុស្សដែលមិនមានលទ្ធភាពផ្គត់ផ្គង់ការចំណាយនៃការប្រឹក្សាផ្នែកច្បាប់ តំណាងផ្នែកច្បាប់ និងការចំណាយក្នុងដំណើរការនៃប្រព័ន្ធតុលាការ។

តាមរយៈគម្រោងសង្ខេបនៃសកម្មភាពអនុវត្តដោយអ្នករាយការណ៍ពិសេសក្នុងឆ្នាំ២០១២ ផ្នែកទាក់ទងនឹងប្រធានបទនៃរបាយការណ៍នេះរួមមាន បីផ្នែក។ ផ្នែកទីមួយ លើកពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ទាក់ទងនឹងជំនួយផ្នែកច្បាប់។ ផ្នែកទីពីរ ផ្តោតសំខាន់លើខ្លឹមសារច្បាប់ទាក់ទងនឹងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងពិនិត្យឡើងវិញនូវករណីយុត្តិសាស្ត្រនៃស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងតុលាការក្នុងតំបន់លើបញ្ហានេះ។ ផ្នែកទីបី មានការវិភាគផ្នែកច្បាប់ ផ្នែកតុលាការ ផ្នែករដ្ឋបាល ផ្នែកថវិកា ផ្នែកអប់រំ និងវិធានការផ្សេងទៀតដែលរដ្ឋត្រូវបានតម្រូវឱ្យអនុវត្តដើម្បីធ្វើឲ្យសិទ្ធិទទួលបានជំនួយផ្នែកច្បាប់មានប្រសិទ្ធិភាពក្នុងសណ្តាប់ធ្នាប់ក្នុងស្រុករបស់រដ្ឋទាំងឡាយ។ ផ្នែកបញ្ចប់នៃរបាយការណ៍នេះ ផ្តល់ជាសេចក្តីសន្និដ្ឋាន និងអនុសាសន៍មួយចំនួនក្នុងគោលបំណងជួយដល់រដ្ឋ និងអ្នកពាក់ព័ន្ធ ក្នុងការអនុម័ត និងអនុវត្តវិធានការ សមរម្យ និងមានប្រសិទ្ធិភាពដើម្បីពង្រឹងការទទួលបានជំនួយផ្នែកច្បាប់នៅក្នុងប្រព័ន្ធយុត្តិធម៌របស់រដ្ឋទាំងឡាយ។

**អត្ថបទពាក់ព័ន្ធដកស្រង់ពីរបាយការណ៍អ្នករាយការណ៍ពិសេស*
*ទទួលបន្ទុកឯករាជ្យភាពរបស់តុលាការ និងមេធាវី*
*ដោយលោកស្រី Gabriela Knaul*

## *៤. សេចក្តីសន្និដ្ឋាន*

៨៦. ជំនួយផ្នែកច្បាប់ គឺជាធាតុផ្សំជាសារវន្តមួយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ប្រកបដោយយុត្តិធម៌ មនុស្សធម៌ និងប្រសិទ្ធផល ដែលផ្អែកលើនីតិរដ្ឋជាមូលដ្ឋាន។ ជំនួយផ្នែកច្បាប់ ជាមូលដ្ឋានគ្រឹះសម្រាប់ការទទួលបានសិទ្ធិផ្សេងៗទៀត ក្នុងនោះរួមមានសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិទទួលបានសំណងដោយប្រសិទ្ធិភាព ដែលជាបុរេល័ក្ខខ័ណ្ឌក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ និងជាកិច្ចធានាការពារដ៏សំខាន់ ដែលធានាឲ្យមានភាពយុត្តិធម៌ជាមូលដ្ឋាន និងជំនឿទុកចិត្តពីសាធារណៈលើដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

៨៧. អ្នករាយការណ៍ពិសេសពិចារណាឃើញថា គោលបំណងនៃជំនួយផ្នែកច្បាប់គឺដើម្បីរួមចំណែកលុបបំបាត់ឧបសគ្គដែលធ្វើឲ្យអន់ថយ និងដាក់កម្រិតលើការទទួលបាននូវយុត្តិធម៌តាមរយៈការផ្តល់ជំនួយដល់មនុស្សដែលមិនមានលទ្ធភាពផ្គត់ផ្គង់ការចំណាយនៃការប្រឹក្សាផ្នែកច្បាប់ តំណាងផ្នែកច្បាប់ និងការចំណាយក្នុងដំណើរការនៃប្រព័ន្ធតុលាការ។ ដោយហេតុនេះ និយមន័យនៃជំនួយផ្នែកច្បាប់គួរតែត្រូវបានបកស្រាយឲ្យមានលក្ខណៈទូលំទូលាយ និងរួមបញ្ចូលការផ្តល់ជំនួយផ្នែកច្បាប់ប្រកបដោយសុវត្ថិភាពក្នុងនីតិវិធីរបស់ប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងកំណត់នូវសិទ្ធិនិង កាតព្វកិច្ច។ លើសពីនេះទៅទៀត ជំនួយផ្នែកច្បាប់មិនគួរត្រូវបានដាក់កំរិតត្រឹមគ្រប់ដណ្តប់លើតែជំនួយផ្នែកច្បាប់ និងតំណាងផ្នែកច្បាប់ក្នុងនីតិវិធីព្រហ្មទណ្ឌ រដ្ឋបាល និងស៊ីវិលប៉ុណ្ណោះទេ ក៏ប៉ុន្តែវាគួរតែរួមបញ្ចូលទាំងការអប់រំផ្នែកច្បាប់ ការទទួលបានព័ត៌មានផ្នែកច្បាប់ និងសេវាផ្សេងៗដែលផ្តល់ដោយយន្តការដោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ និងដំណើរការស្តាបនាយុត្តិធម៌ឡើងវិញ។

៨៨. យោងតាមនិយមន័យលក្ខណៈទូលំទូលាយនៃសេវាជំនួយផ្នែកច្បាប់ អ្នករាយការណ៍ពិសេសជឿជាក់ថា គំនិតនៃអ្នកទទួលផលពីជំនួយផ្នែកច្បាប់មិនគួររួមបញ្ចូលតែជនជាប់ចោទក្នុងនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះទេ ប៉ុន្តែគួរតែរាប់បញ្ចូលទាំង (ក) បុគ្គលទាំងឡាយដែលសិទ្ធិ ឬសេរីភាពរបស់ពួកគេត្រូវបានរំលោភដោយរដ្ឋ កើតឡើងពីសកម្មភាព ឬការខកខាន

មិនបានធ្វើសកម្មភាពរបស់រដ្ឋនោះ និង (ខ) បុគ្គលទាំងឡាយដែលចូលរួមក្នុងនីតិវិធីតុលាការ និងក្រៅនីតិវិធីប្រព័ន្ធតុលាការ ក្នុងគោលបំនង កំណត់នូវសិទ្ធិ និងកាតព្វកិច្ច ក្នុងរឿងក្តីចំពោះមុខច្បាប់"។

៨៩. រដ្ឋមានបន្ទុកទទួលខុសត្រូវចម្បងក្នុងការអភិវឌ្ឍ និងអនុវត្តប្រព័ន្ធជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាព និង និរន្តភាពដោយផ្អែកលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងការអនុវត្តដ៏ល្អដែលត្រូវបានទទួលស្គាល់។ ប្រសិនបើសិទ្ធិទទួល បានជំនួយផ្នែកច្បាប់នៅមិនទាន់បានធានាដោយច្បាប់ និងការអនុវត្តជាតិនៅឡើយទេ រដ្ឋត្រូវបានតម្រូវឲ្យធ្វើការកែប្រែ ផ្លាស់ប្តូរទៅលើច្បាប់ និងការអនុវត្តជាតិតាមការចាំបាច់ ដើម្បីធានានូវការអនុលោមទៅតាមកាតព្វកិច្ចអន្តរជាតិផ្នែកច្បាប់ របស់រដ្ឋ ដែលពួកគេបានអនុវត្ត។ ប្រព័ន្ធជំនួយផ្នែកច្បាប់គួរតែត្រូវបានធ្វើស្ថាបនាកម្ម ដើម្បីឲ្យប្រព័ន្ធនេះអាចត្រូវបានរៀបចំ និងពិនិត្យតាមដានត្រឹមត្រូវ ហើយមន្ត្រីផ្តល់សេវាជំនួយផ្នែកច្បាប់អាចត្រូវទទួលខុសត្រូវក្នុងករណីដែលពួកគេមិនបាន ផ្តល់សេវាឲ្យបានគ្រប់គ្រាន់ សមរម្យ ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាព។

៩០. អ្នករាយការណ៍ពិសេសកត់សម្គាល់ថា ក្នុងការអនុវត្ត ប្រទេសជាច្រើននៅមានការខ្វះខាតផ្នែកធនធាន និងសមត្ថភាពដែលចាំបាច់សម្រាប់លើកស្ទួយសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃរបស់បុគ្គលគ្រប់រូប ហើយក៏ សម្គាល់ឃើញថា កង្វះខាតមូលនិធិដើម្បីធានាការគាំទ្រផ្នែកច្បាប់សម្រាប់បុគ្គលដែលមិនមានមធ្យោបាយហិរញ្ញវត្ថុ គ្រប់គ្រាន់ធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះការទទួលបានយុត្តិធម៌របស់ពួកគេ ហើយជាលទ្ធផល ការទទួលបានសិទ្ធិផ្សេងៗ និងសេរីភាពជាមូលដ្ឋានដោយស្មើភាពគ្នា និងមានប្រសិទ្ធិភាពក៏ត្រូវប៉ះពាល់ផងដែរ។

## *៥. អនុសាសន៍*

៩១. ផ្អែកតាមគោលការណ៍ និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិស្តីពីការទទួលបានជំនួយផ្នែកច្បាប់នៅក្នុង ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ អ្នករាយការណ៍ពិសេសផ្តល់អនុសាសន៍ដូចខាងក្រោមក្នុងគោលបំនងជួយដល់រដ្ឋក្នុងការអភិវឌ្ឍ និងអនុវត្តវិធានការសមរម្យ និងប្រកបដោយប្រសិទ្ធិភាពដើម្បីពង្រឹងការទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ របស់ខ្លួន។

## ក. ច្បាប់ស្តីពីជំនួយផ្នែកច្បាប់

៩២. សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ គួរត្រូវបានធានាដោយស្របច្បាប់ក្នុងប្រព័ន្ធច្បាប់ជាតិនៅកម្រិតខ្ពស់បំផុតដែល អាចធ្វើទៅបាន ប្រសិនបើអាចគឺត្រូវធានាដោយរដ្ឋធម្មនុញ្ញ។

៩៣. រដ្ឋត្រូវពិចារណាអនុម័តច្បាប់ជាក់លាក់ ដើម្បីបង្កើតប្រព័ន្ធជំនួយផ្នែកច្បាប់ទូលំទូលាយមួយដែលអាចធ្វើឲ្យការ ទទួលបាន ប្រកបដោយប្រសិទ្ធិភាព និរន្តភាព និងអាចជឿជាក់បាន។

៩៤. ច្បាប់ស្តីពីជំនួយផ្នែកច្បាប់គួរតែ៖

(ក) មាននិយមន័យជំនួយផ្នែកច្បាប់លក្ខណៈទូលំទូលាយ;

(ខ) អភិវឌ្ឍលក្ខណៈវិនិច្ឆ័យជាក់លាក់ដើម្បីកំណត់សិទ្ធិទទួលបានជំនួយផ្នែកច្បាប់;

(គ) ធានាថា ជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពត្រូវបានផ្តល់ឲ្យនៅគ្រប់ដំណាក់កាលនៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ នៅដំណាក់កាលបុរេវិនិច្ឆ័យ និងនៅក្នុងនីតិវិធីតុលាការណាមួយដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬនីតិវិធីក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំនងកំណត់សិទ្ធិ និងកាតព្វកិច្ច;

(ឃ) ធានាថា ធានាថាព័ត៌មានអំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងអ្វីដែលជំនួយនោះផ្តល់ឲ្យ រួមបញ្ចូលទាំងភាពអាចរកបាននៃសេវាជំនួយផ្នែកច្បាប់ និងមធ្យោបាយដើម្បីទទួលបានជំនួយនោះ ត្រូវបានដាក់ឲ្យអាចរកបានដល់សាធារណៈជនទូទៅ តាមរយៈមធ្យោបាយសមរម្យទាំងឡាយ ដូចជាប្រព័ន្ធផ្សព្វផ្សាយ និងអ៊ីនធើណេត ក៏ដូចជានៅក្នុងមណ្ឌលណាមួយ ដែលជាកន្លែងដែលមនុស្សជាប់ពន្ធនាគារ ឬត្រូវបានឃុំខ្លួន;

(ង) កំណត់លក្ខណៈសម្បត្តិអប្បបរមា និងបណ្តុះបណ្តាលអ្នកជំនាញ និងអ្នកជំនួយមេធាវីដែលធ្វើការឲ្យប្រព័ន្ធជំនួយផ្នែកច្បាប់។

## ខ. ការបង្កើតប្រព័ន្ធជាតិជំនួយផ្នែកច្បាប់

៩៥. រដ្ឋគួរកំណត់នូវគំរូមួយ ដែលអាចពង្រីកនូវការទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ សម្រាប់បុគ្គលគ្រប់រូបនៅក្នុងទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងចំណោមគំរូសម្រាប់ការផ្តល់ជំនួយផ្នែកច្បាប់ផ្សេងៗ ដោយពិចារណាទៅលើវិសាលភាព និងការផ្តល់មូលនិធិរបស់គម្រោងជំនួយផ្នែកច្បាប់ ប្រភេទនៃប្រព័ន្ធយុត្តិធម៌របស់ខ្លួន និងតំបន់នៃដែនសមត្ថកិច្ចដែលខ្លួនមានមុខងារ។

៩៦. រដ្ឋគួរពិចារណាបង្កើតភ្នាក់ងារ ឬអាជ្ញាធរជំនួយផ្នែកច្បាប់ឯករាជ្យ ដូចជាការិយាល័យអ្នកការពារសាធារណៈ ដែលផ្តល់ គ្រប់គ្រង សម្របសម្រួល និងពិនិត្យសេវាជំនួយផ្នែកច្បាប់។ គម្រោងជំនួយផ្នែកច្បាប់របស់រដ្ឋ ដោយមិនគិតពីរចនាសម្ព័ន្ធរដ្ឋបាល គួរមានសេរីភាពពីការជ្រៀតជ្រែកយ៉ាងលើសលប់ខាងនយោបាយ ឬ តុលាការ និងឯករាជ្យពីរាជរដ្ឋាភិបាលក្នុងការធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់។

៩៧. នៅពេលដែលទំនួលខុសត្រូវក្នុងការផ្តល់ជំនួយផ្នែកច្បាប់ត្រូវបានចែករំលែកក្នុងចំណោមស្ថាប័នរដ្ឋ និងមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ក្រៅរដ្ឋាភិបាល យន្តការសមរម្យគួរតែត្រូវបានអនុវត្តដើម្បីជួយសម្របសម្រួលរវាងមន្ត្រីផ្តល់ជំនួយផ្នែកច្បាប់ផ្សេងៗគ្នា ដែលជាលទ្ធផល ពង្រីកប្រសិទ្ធិភាពរបស់ប្រព័ន្ធជំនួយផ្នែកច្បាប់។

៩៨. រដ្ឋគួរជំរុញគណៈមេធាវីឲ្យអភិវឌ្ឍកម្មវិធីជំនួយផ្នែកច្បាប់ ឬគាំទ្រប្រព័ន្ធដែលមានស្រាប់ ដើម្បីធានាភាពទូលំទូលាយនៃការទទួលបានសេវាជំនួយផ្នែកច្បាប់ដែលបានផ្តល់ឲ្យ ឬជំនួយផ្នែកច្បាប់ដោយមិនគិតកំរៃ។ ក្នុងករណីសមរម្យ រដ្ឋគួរបង្កើតភាពជាដៃគូជាមួយគណៈមេធាវី និងការិយាល័យជំនួយផ្នែកច្បាប់ ដើម្បីធានាថា ជំនួយផ្នែកច្បាប់ត្រូវបានផ្តល់ឲ្យនៅគ្រប់ដំណាក់កាលនីតិវិធីព្រហ្មទណ្ឌ នៅតំណាក់កាលបុរេវិនិច្ឆ័យ និងនៅក្នុងនីតិវិធីតុលាការណាមួយដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬនីតិវិធីក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំនងកំណត់សិទ្ធិ និងកាតព្វកិច្ច។

៩៩. រដ្ឋគួរអនុវត្តវិធានការសមរម្យដើម្បីលើកស្ទួយការគាំទ្រ និងការបង្កើតការិយាល័យដូចរៀបរាប់ខាងលើនៅនាយកដ្ឋានច្បាប់នៃសកលវិទ្យាល័យ និងផ្តល់គ្រឿងលើកទឹកចិត្តដល់និស្សិតផ្នែកច្បាប់ឲ្យចូលរួមក្នុងគម្រោងជំនួយផ្នែកច្បាប់ ជាផ្នែកមួយនៃកម្មវិធីសិក្សា ឬការអភិវឌ្ឍខាងវិជ្ជាជីវៈច្បាប់។

១០០. ក្នុងករណីមានមេធាវីជំនាញមិនគ្រប់គ្រាន់ រដ្ឋគួរអភិវឌ្ឍបណ្ដាញសេវាអ្នកជំនួយមេធាវីទូទាំងប្រទេស ជាមួយនឹងកម្មវិធីបណ្ដុះបណ្ដាល ដែលត្រូវធ្វើឲ្យទៅជាស្តង់ដា និងគម្រោងទទួលស្គាល់ជាផ្លូវការ។

១០១. ក្នុងកិច្ចសហការជាមួយមន្ត្រីផ្ដល់សេវាផ្នែកច្បាប់ឯកជន រដ្ឋគួរអភិវឌ្ឍលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់ជាផ្លូវការចំពោះមន្ត្រីផ្ដល់ជំនួយផ្នែកច្បាប់; ធានាថាមន្ត្រីជំនួយផ្នែកច្បាប់គោរពតាមក្រមសីលធម៌វិជ្ជាជីវៈដែលអាចអនុវត្តបាន; អនុវត្តយន្តការដើម្បីធានាថាមន្ត្រីជំនួយផ្នែកច្បាប់ទាំងអស់មានការអប់រំ ការបណ្ដុះបណ្ដាល ជំនាញ និងបទពិសោធន៍សមស្របនឹងប្រភេទនៃការងាររបស់ពួកគេ; ព្រមទាំងរៀបចំបង្កើតយន្តការត្រួតពិនិត្យសមស្របនានាសម្រាប់មន្ត្រីជំនួយផ្នែកច្បាប់ ជាពិសេសក្នុងគោលបំណងបង្ការការទទួលបានប្រាក់កំរៃពីអ្នកទទួលផលជំនួយផ្នែកច្បាប់ លើកលែងតែករណីដែលត្រូវបានអនុញ្ញាត។

## គ. ការផ្ដល់មូលនិធិគម្រោងជំនួយផ្នែកច្បាប់

១០៣. ដោយមិនគិតពីប្រភេទ និងគំរូនៃគម្រោងជំនួយផ្នែកច្បាប់ រដ្ឋគួរផ្ដល់ថវិកាសម្រាប់សេវាជំនួយផ្នែកច្បាប់ដែលសមស្របទៅនឹងសេចក្ដីត្រូវការរបស់ខ្លួន។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋទាំងឡាយអាចចាត់វិធានការរៀបចំបង្កើតមូលនិធិជំនួយផ្នែកច្បាប់ ដើម្បីផ្ដល់ថវិកាដល់គម្រោងជំនួយផ្នែកច្បាប់ និង កំណត់យន្តការសារពើពន្ធសម្រាប់បញ្ជូនមូលនិធិដល់ជំនួយផ្នែកច្បាប់។

១០៤. ដើម្បីជាជំនួយដល់ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធជំនួយផ្នែកច្បាប់ជាតិ ទីភ្នាក់ងារឯកទេស កម្មវិធី និងមូលនិធិអង្គការសហប្រជាជាតិ រដ្ឋទាំងឡាយ ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល គួរផ្ដល់ជំនួយបច្ចេកទេសផ្អែកលើសេចក្ដីត្រូវការ និងអាទិភាពដែលបានកំណត់ដោយរដ្ឋស្នើសុំទាំងឡាយ នៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការទ្វេភាគី និងពហុភាគី។

## ឃ. ជំនួយផ្នែកច្បាប់សំរាប់ស្ត្រី កុមារ និងក្រុមមនុស្សដែលមានសេចក្ដីត្រូវការពិសេស

១០៥. ដោយទទួលស្គាល់ថាកង្វះគោលនយោបាយសាធារណៈដើម្បីលុបបំបាត់ឧបសគ្គរាំងដល់ការទទួលបានយុត្តិធម៌សម្រាប់បុគ្គលគ្រប់រូប មានផលប៉ះពាល់កាន់តែខ្លាំងចំពោះក្រុមមនុស្សស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ឬរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ រដ្ឋគួរអភិវឌ្ឍ និងអនុវត្តគោលនយោបាយសមរម្យដើម្បីធានាការទទួលបានជំនួយផ្នែកច្បាប់ដ៏មានន័យសម្រាប់ស្ត្រី កុមារ និងក្រុមមនុស្សដែលមានសេចក្ដីត្រូវការពិសេស។